ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៧ អនក្រ.បក

អនុក្រឹត្យ

កែសំរួលស្តីពី ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រី រាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៥

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ សេចក្តីសំរេចរបស់ក្រុមប្រឹក្សារាជសម្បត្តិ លេខ គរស/សសរ/១០០៤/០០១ ចុះថ្ងៃ ១៤ តុលា ឆ្នាំ ២០០៤ ស្តីពីការជ្រើសរើសព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់ពេលបំរើការងារប្រចាំសប្តាហ៍របស់មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ

<u>ស ម្រេ ច</u>

<u>មាត្រា</u> ១.-

ត្រូវបានកែប្រែអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៤ ហើយត្រូវ អនុញ្ញាតអោយមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ បានឈប់សម្រាកការងារ ឆ្នាំ ២០០៥ តាមប្រតិទិន ដូចខាងក្រោម :

- ថ្ងៃទី ០១	មករា	ទិវាចូលឆ្នាំសកល	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ០៧	មករា	ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ២៣	កុម្ភៈ	ពិធីបុណ្យមាឃបូជា	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ០៨	មីនា	ទិវានារីអន្តរជាតិ	សម្រាក ០១ ថ្ងៃ

www.pheakdeylaw.com

- ថ្ងៃទី ១៤-១៥-១៦	មេសា	ពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ	សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ០១	ឧសភា	ទិវាពលកម្មអន្តរជាតិ	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៣-១៤-១៥	ឧសភា	ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា	សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ២២	ឧសភា	ពិធីបុណ្យវិសាខបូជា	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ២៦	ឧសភា	ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៨	មិថុនា	ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ	សម្រាក ០១ ថ្ងៃ
-ថ្ងៃទី ២៤	កញ្ញា	ទិវាប្រកាសរដ្ឋធម្មនុញ្ញ	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ០២-០៣-០៤	តុលា	ពិធីបុណ្យភ្ជុំបិណ្ឌ	សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ២៩	តុលា	ព្រះរាជពិធីគ្រងរាជសម្បត្តិរបស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ៣១	តុលា	ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះវររាជបិតា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ០៩	វិច្ឆិកា	ពិធីបុណ្យឯករាជ្យជាតិ	សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៥-១៦-១៧	វិច្ឆិកា	ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក	សម្រាក ០៣ ថ្ងៃ
-ថ្ងៃទី ១០	ធ្នូ	ទិវាសិទ្ធិមនុស្សអន្តរជាតិ	សម្រាក ០១ ថ្ងៃ

មាត្រា ២.-

ពេលវេលាឈប់សម្រាកទាំងឡាយណាដែលត្រូវចំថ្ងៃណាមួយនៃថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ (សៅរ៍ ឬ អាទិត្យ) ត្រូវបានអោយឈប់ចំនួន ០១ ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត ។ ប៉ុន្តែ ក្នុងករណីត្រូវចំទាំងពីរថ្ងៃជាប់គ្នា គឺទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវអនុញ្ញាតអោយឈប់សម្រាកបន្ថែមជាជំនួស គឺឈប់តែ ០១ ថ្ងៃប៉ុណ្ណោះ ។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com